ថ្មីៗនេះលោកគ្រូ រ៉ូប៊ីន ត្រូវបានអញ្ជើញដោយសហព័ន្ធអ្នកដឹកនាំគ្រីស្ទានជាតិ ដើម្បីសរសេរនូវអត្ថបទមួយ ដែលបានបោះពុម្ពចេញផ្សាយនៅដើមខែមិថុនា ។ សូមអានសេចក្តីផ្តើមរបស់សហព័ន្ធដូចខាងក្រោម៖

«ការប្រឈមរបស់យើងមិនគ្រាន់តែតភ្ជាប់ទៅក្នុងពិភពលោកមួយយ៉ាងធំនោះទេ តែក៏ដើម្បីនាំនូវព្រះបន្ទូលដ៏មានជាតិប្រៃរបស់ព្រះគ្រីស្ទជាព្រះសង្គ្រោះយើងរាល់គ្នាផងដែរ! មនុស្សដែលទទួលបានការហ្វឹកហាត់ជាមួយវិទ្យាសាស្ត្រនឹងទទួលស្គាល់ភ្លាមៗអំពីភាពរៀងរយរបស់ សម្ព័ន្ធភាពអ្នកដឹកនាំគ្រីស្ទបរិស័ទជាតិ the National Alliance of Christian Leadership – NACL ដែលមានអក្សរកាត់ NACL ។

ផ្នែកមួយនៃការងារគ្រីស្ទបរិស័ទគឺ ដើម្បីបម្រើជាអំបិល និងពន្លឺនៅក្នុងពិភពលោក គឺដើម្បីបញ្ជាក់សារតីដោយត្រង់ចែករំលែកការពិត។

នៅក្នុងខែនេះ លោកគ្រូ Robin Johnson រ៉ូប៊ីន មកពី ប៊ីយនហ៊ា អ៊ីនទ័រណាសិនណល់ លោកនឹងជំរុញយើងរាល់គ្នាមិនឲ្យរង្វេងផ្លូវនៃសេចក្តីពិតឡើយ ។ ខ្ញុំសង្ឃឹមថាលោកអ្នកនឹងរីករាយនៅក្នុងការអានអំពីការចែករំលែករបស់លោកគ្រូ»

សេចក្តីពិតអំពីការពិត

ដោយ រ៉ូប៊ីន ជេ. ចនសុន

ពួកយើងដែលជាអ្នកមានជំនឿក្នុងព្រះគ្រីស្ទ និងជាអ្នកតាមព្រះយេស៊ូវគ្រីស្ទ សេចក្តីពិតគឺជាគោលការណ៍ដ៏ចាំបាច់ខាន ដែលបានស្ថិតនៅលើព្រះបន្ទូលទាំងមូលរបស់ព្រះ ហើយមិនចេះពុករលួយ និងមិនផ្លាស់ប្តូរឡើយ។ យើងជឿ និងប្រកាន់ខ្ជាប់តាមការបង្រៀនរបស់ព្រះគ្រីស្ទ ដូចដែលបានបង្ហាញនៅក្នុងព្រះបន្ទូល។ សេចក្តីពិតគឺជាមូលដ្ឋានដែលជីវិតយើងត្រូវបានកសាងឡើង។ យើងមិនចាំបាច់កែប្រែ ឬធ្វើឲ្យទាន់សម័យណាមួយឡើយជាមួយពេលបច្ចុប្បន្ននេះ។

ជំនឿរបស់យើងបានបង្កើតឡើងលើសេចក្តីពិត ដែលត្រូវឆ្លុះបញ្ចាំងនៅក្នុងអាកប្បកិរិយា និងទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃ។ លោកសាវកប៉ុល បានសរសេរនិងណែនាំដល់ជឿទាំងអស់ថា៖

"កុំឲ្យកុហកគ្នាទៅវិញទៅមក" កូឡុស ៣:៩

សញ្ញាបង្ហាញពីជីវិតថ្មីក្នុងព្រះគ្រីស្ទ គឺការប្តេជ្ញាចិត្តក្នុងការរស់នៅដោយសេចក្តីពិត។ ប៉ុលក៏បានប្រៀបធៀបការកុហកជាអំពើអាក្រក់ដែលយើងធ្លាប់ធ្វើមុនពេលទទួលការសង្គ្រោះ។

សេចក្តីពិតអំពីសេចក្តីពិត គឺមានន័យថា វាមិនផ្លាស់ប្តូរឡើយ។ វាជាសេចក្តីពិត ការពិត ការពិតប្រាកដមិនគិតរយៈពេល ឬស្ថានភាពទេនោះទេ។ វាជាគុណភាពដើម និងជាគោលការណ៍នៃភាពពិត។ វាពិតសម្រាប់គ្រប់គ្នា នៅគ្រប់ទីកន្លែង ទាំងពេលវេលាកន្លងទៅ និងបច្ចុប្បន្ន។

សង្គមសព្វថ្ងៃតែតែបណ្តុះបណ្តាលមនុស្សឲ្យជឿលើអ្វីដែលពាក់កណ្តាល ពិត និងមិនពិត។ ខ្លះនិយាយថា **"សេចក្តីពិតគឺអ្វីដែលអ្នកចង់ឲ្យវាទៅជាបែបយ៉ាងណា ទៅបែបយ៉ាងនោះ"** ។ បច្ចុប្បន្នក៏មានសារព័ត៌មានមួយចំនួន ដែលបានប្រែក្រឡាស់ពីសរទៅខ្មៅផងដែរ ។ ខ្ញុំធ្លាប់មើលព័ត៌មានពេលល្ងាច ហើយមានព័ត៌និយាយ

អំពីមនុស្សម្នាក់ដែលខ្ញុំស្គាល់ អ្នកយកព័ត៌មានបានកែប្រែអង្គហេតុឱ្យសមនឹងការនិទានរឿងរបស់គាត់វិញ ដោយធ្វើរបាយការណ៍ពីសទៅខ្មៅ ទៅជាអង្គហេតុមិនពិតប្រាកដ ។ ជាច្រើនលើកច្រើនសារ ដែលខ្ញុំបាននិយាយលេងៗទៅកាន់ភរិយារបស់ខ្ញុំថា៖ **"ហេតុអ្វីចាំបាច់ឲ្យសេចក្តីពិតរំខានរឿងល្អមួយបែបនេះ?"**

ក្នុងពិភពលោកនេះយើងនេះ សេចក្តីពិតត្រូវបានចុះអន់ថយ ហើយជំនួសដោយការកុហក ដែលមនុស្សគិតថា គឺជារឿងធម្មតា ជាពិសេសសម្រាប់មនុស្សដែលកំពុងតែស្វែងរកនូវ អំណាច និងឥទ្ធិពល ។ នេះគឺជាការឆ្លុះបញ្ចាំងដ៏ក្រៀមក្រំមួយសម្រាប់ពេលបច្ចុប្បន្ននេះ ដែលយើងកំពុងរស់នៅ។

ពេលខ្លះភាពស្មោះត្រង់ ត្រូវបានលះបង់ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន។ ដើម្បីឲ្យខ្លួនអ្នកបានការងារល្អជាងនេះ ឬអ្នកនយោបាយក៏ខំប្រឹងលះបង់ភាពស្មោះ ដើម្បីឲ្យទទួលបានសន្លឹកឆ្នោតច្រើនជាងមុន។

នៅពេលដែលខ្ញុំក្មេងនៅឡើយ ម្តាយខ្ញុំបាននិយាយពាក្យមួយដែលខ្ញុំមិនភ្លេចរហូតមកដល់ពេលនេះ។ បើទោះបីខ្ញុំមិនបានជឿលើពាក្យនោះក៏ដោយ តាំងពីពេលដែលខ្ញុំនៅវ័យក្មេងរហូតដល់វ័យជំទង់ក៏ដោយ។ ខ្ញុំមិនចាំថាព្រឹត្តិការណ៍ពិត ឬការសន្ទនាទាំងអស់ផងដែរ ដែលម្តាយខ្ញុំបានប្រាប់ដល់ខ្ញុំ ប៉ុន្តែ អ្វីដែលគាត់បាននិយាយមួយចំណុចដែលពាក្យនោះបានពាក់ពាល់ខ្ញុំគឺថា៖
"ឪពុកអ្នកមិនកុហស ដើម្បីឲ្យបានសង្គ្រោះជីវិតរបស់ខ្លួនទេ!"

"ពាក្យសំដីខ្ពស់ប្រសើរ មិនសំណាំនឹងមនុស្សល្ងីល្ងើទៅហើយ ចំណង់បើបបូរមាត់កំភូត តើមិនសំណាំនឹងមនុស្សត្រកូលខ្ពស់ជាជាងយ៉ាងណាទៅ។" សុភាសិត ១៧:៧

សេចក្តីពិត គឺជាគ្រឹះដ៏រឹងមាំ ដោយគ្មានភាពស្មោះត្រង់ ឬភាពរឹងមាំយូរអង្វែងនៅក្នុងទំនាក់ទំនង។ នៅពេលដែលនរណាម្នាក់បានកុហកអ្នក វាក្លាយជាការលំបាកក្នុងការបន្តធ្វើការជាមួយពួកគេ។ ជាក់ស្តែង ការអភ័យទោសមានតួនាទីក្នុងការបញ្ចេញ ប៉ុន្តែការកុហកបំផ្លាញទំនុកចិត្ត។ នៅពេលដែលការជឿទុកចិត្តត្រូវបានខូច វាពិបាកក្នុងការធ្វើជួសជុលឲ្យល្អដូចដើមណាស់។ ខ្ញុំមិនអាចនិយាយថា វាមិនអាចស្តារមកវិញមិនបាននោះទេ ប៉ុន្តែវាមិនងាយស្រួលទេ។

នៅពេលដែលយើងបានអានព្រះគម្ពីរសញ្ញាថ្មី យើងនឹងគ្មានការងឿងឆ្ងល់ទេថា សេចក្តីពិតគឺជាគ្រឹះសម្រាប់សេចក្តីជំនឿ និងការប្រព្រឹត្ត។ លោកប៉ុលនិយាយ ពីជីវិតថ្មីរបស់យើងនៅក្នុងព្រះគ្រីស្ទ ដែលបានបង្កើតឡើងដោយភាពសុចរិត និងបរិសុទ្ធ ដោយសារសេចក្តីពិត។

"ដូច្នេះ ដែលបានដោះសេចក្តីកំភូតចេញហើយ នោះត្រូវឲ្យនិយាយសេចក្តីពិត នឹងអ្នកជិតខាងរៀងខ្លួនវិញ ដ្បិតយើងរាល់គ្នាជាអវយវៈផងគ្នាទៅវិញទៅមក" (អេភេសូរ ៤:២៥)

ជាមូលដ្ឋានគ្រឹះនៃជីវិត និងដើម្បីឲ្យការទំនាក់ទំនងទាំងអស់បាននៅជាប់ស្ថិតស្ថេរយូរអង្វែងនោះ យើងម្នាក់ៗត្រូវតែមាន **សេចក្តីពិត** ក្នុងខ្លួន។

ជីវិត និងទំនាក់ទំនងណាមួយ ដែលត្រូវធន់នឹងសម្ពាធ ត្រូវការមូលដ្ឋានជា **សេចក្តីពិត** ។ ខ្ញុំបានឃើញក្នុងជីវិតមនុស្សជាច្រើនទទួលបរាជ័យ ដោយសារការបដិសេធ**សេចក្តីពិត** ។ នៅពេលដែលយើងបដិសេធ ហើយដើរចេញពី**សេចក្តីពិត** យើងមិនកំពុងតែចូលទៅក្នុងកន្លែងណាមួយពិតប្រាកដនោះទេ ផ្ទុយទៅវិញយើងកំពុងតែចូលទៅក្នុងកន្លែង ដែលពោរពេញទៅដោយការមិនពិត និងការបោកប្រាស់។ ការបោកបញ្ឆោត គឺជាផលផ្លែ នៅពេលដែលយើងបានបដិសេធការពិត ដូចដែលលោកប៉ុលបានចែងក្នុង **រ៉ូម ១:២៥**

ជាការចាំបាច់ដែលនៅក្នុងជីវិត និងកិច្ចការងារបម្រើព្រះរបស់យើងត្រូវបានក៏សាងឡើងដោយ**សេចក្តីពិត**។ អ្នកដឹកនាំគ្រីស្ទបរិស័ទត្រូវតែប្រយ័ត្ន កុំឱ្យជាប់អន្ទាក់ដោយសារពិភពលោក និងអ្វីៗរបស់លោកីយនេះអោយសោះ។ ភាពសុច្ចៈស្មោះត្រង់ផ្ទាល់ខ្លួនរបស់យើង ត្រូវតែមានតម្លៃ និងត្រូវតែបានទទួលការការពារ។ ដើម្បីកសាងជីវិតយើងលើសេចក្តីពិត យើងត្រូវត្រៀមខ្លួន ដើម្បីការពារពីខ្មាំងសត្រូវ និងឈរលើសេចក្តីពិត។ ដូចព្រះដ៏មានព្រះចេស្តាទ្រង់មានបន្ទូលថា៖

"នេះជាការដែលឯងរាល់គ្នាត្រូវធ្វើ គឺត្រូវឲ្យគ្រប់គ្នានិយាយសេចក្តីពិតនឹងអ្នកជិតខាងខ្លួន ហើយត្រូវឲ្យសំរេចតាមសេចក្តីយុត្តិធម៌ដ៏ពិត និងសេចក្តីសុខ នៅក្នុងទ្វារក្រុងរបស់ឯងរាល់គ្នា ១៧ កុំឲ្យពួកឯងណាមួយគិតគូរបង្កើតការអាក្រក់ក្នុងចិត្តទាស់នឹងអ្នកជិតខាងខ្លួនឡើយ ក៏កុំឲ្យចូលចិត្តនឹងពាក្យស្បថកំភូតដែរ ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញស្អប់អស់ទាំងអំពើយ៉ាងនោះណាស់។" *សាការី ៨:១៦-១៧*

ការសរសេរអំពីសង្គ្រាមខាងវិញ្ញាណ លោកសាវ័កប៉ុលបានរៀបរាប់លម្អិតអំពីគ្រឿងសឹករបស់ព្រះ ដែលត្រូវបានផ្តល់ជូនសម្រាប់ អ្នកជឿត្រូវឈរយ៉ាងរឹងមាំក្នុងសមរភូមិ។ គាត់ចាប់ផ្តើមដោយប្រាប់យើងឱ្យពាក់ខ្សែក្រវ៉ាត់នៃសេចក្តីពិត (**អេភេសូរ ៦:១០-១៤**)។ ក្នុងរឿងប្រៀបប្រដូចនេះគឺជាចំណុចចាប់ផ្តើមជាមូលដ្ឋាននិងអាចទាញយកបាន។ សេចក្តីសុចរិត យើងត្រូវតែធ្វើតាម ហើយត្រូវតែនៅជាប់ទីកន្លែងនៃសេចក្តីពិត។ សម្រាប់គោលលទ្ធិ និងការសម្រាកពិតប្រាកដរបស់គ្រីស្ទបរិស័ទនោះ គឺមានតែលើ **ថ្មដា** តែប៉ុណ្ណោះ។

ហេតុដូច្នេះហើយ យើងមិនរស់នៅដោយម្ចាស់ខ្លួនឯងនោះទេ តែយើងត្រូវរស់ដោយឈរលើការពិត ហើយនិយាយការពិតទៅវិញទៅមក ប៉ុន្តែយើងក៏ត្រូវត្រៀមខ្លួនដើម្បីការពារការសេចក្តីពិត និងត្រៀមខ្លួនដើម្បីនិយាយប្រឆាំងនឹងការកុហក ហើយការបោកបញ្ឆោតមានច្រើនក្នុងនៅសង្គម។ វាត្រូវបានគេនិយាយថា ប្រសិនបើអ្នកនិយាយកុហកញឹកញាប់គ្រប់គ្រាន់នោះនៅទីបំផុតអ្នកនឹងជឿវា។ នេះជាការពិតជាបុគ្គល និងសង្គមទាំងមូល។

ប៉ុន្តែយើងត្រូវត្រៀមខ្លួន ដើម្បីការពារការពិត និងត្រៀមខ្លួនដើម្បីនិយាយទាស់នឹងការកុហក ហើយការបោកបញ្ឆោតមានច្រើនក្នុងសង្គម។ ប្រសិនបើអ្នកនិយាយកុហកញឹកញាប់ ហើយអ្នកបានទទួលស្គាល់អំពីការនោះ នោះវាជាសេចក្តីពិតសម្រាប់អ្នក បន្ទាប់មកទៀតមនុស្សនៅជុំវិញអ្នកនឹងបានដឹងអំពីទង្វើរបស់អ្នកផងដែរ។ ខាងក្រោមនេះ ជាឧទាហរណ៍មួយចំនួនដែលពាក់ព័ន្ធនៅពេលសព្វថ្ងៃនេះ៖

- សេវាកម្មរំលូតកូនឈានមុខគេបានធ្វើផ្សព្វផ្សាយថា "យើងកំពុងផ្តល់សេវាកម្មមេត្តាករុណាដល់ស្ត្រី" **មិនពិតទេ** ។ គ្មានសេចក្តីមេត្តាណាមួយសម្រាប់ស្ត្រីដែលរងរបួស ឬកុមារដែលបានស្លាប់មុនពេលកើតមកឡើយ។

- "កេទគឺមាននៅក្នុងខ្លួនមនុស្សយើងតាំងពីដើមម្ល៉េះ ហើយវាក៏អាចផ្លាស់ប្តូរបានផងដែរ" **មិនពិតទេ**។ កេទគឺត្រូវបានកំណត់ និងពុំអាចផ្លាស់ប្តូរនោះឡើយ។

- "ការរួមភេទ ភេទដូចគ្នា និងរៀបការភេទដូចគ្នា ជាការធម្មតា" **មិនពិតទេ**។ ភាពស្និទ្ធស្នាលផ្លូវភេទ គឺបង្កើតឡើងរវាងបុរស និងស្ត្រី ក្នុងអាពាហ៍ពិពាហ៍ឯកត្តជនដ៏មានសេចក្តីស្រឡាញ់។

ជាចុងក្រោយ ការកុហកដ៏ធំបំផុតមួយក្នុងចំណោមនោះគឺថា (ដែលបានរៀបរាប់ខាងលើ និងការផ្សេងទៀត) គឺជាបញ្ហានយោបាយ និងការទំនាក់នងការងារផ្សេងៗដែលមិនច្បាស់លាស់ ដែលពួកជំនុំមិនគួរពាក់ព័ន្ធ។

ជាចុងក្រោយ ការកុហកឬសេចក្តីមិនពិត ដ៏ធំបំផុតមួយគឺថានៅចំណុចទាំងនេះ (ដែលបានលើកឡើងនូវខាងលើ និងការកុហកផ្សេងទៀត) គឺជាបញ្ហានយោបាយ និងជាការសន្ទនាដែលពួកជំនុំមិនគួរពាក់ព័ន្ធ។ តើវាជាការពិត ដែលថាព្រះវិហារជាច្រើនបានធ្វេសប្រហែសក្នុងការបញ្ចេញសំឡេងក្នុងវិស័យសំខាន់ៗ ហើយនេះបាននាំឲ្យមានស្ថានភាពដែលយើងមានសព្វថ្ងៃ? ការពិតមិនត្រូវបានគេនិយាយ ឬបានឮទេ ហើយការកុហកបានចាក់ឫសហើយឥឡូវនេះបានឈ្នះហើយ។

ទំនុកដំកើងបានចែកថា **"បើសិនជាគោលប្រជានត្រូវបំផ្លាញនោះតើមនុស្សសុចរិតនឹងអាចធ្វើអ្វីបាន?" ទំនុកតម្កើង ១១:៣** ដើម្បីឲ្យមូលដ្ឋាននៃសេចក្តីពិតនៅតែរឹងមាំ និងប្រាកដ លុះត្រាតែយើងត្រៀមខ្លួនដើម្បីឈរយ៉ាងពិត ហើយនិយាយសេចក្តីពិត នោះពាក្យកុហកនឹងសាបពីក្នុងចិត្ត និងគំនិតរបស់មនុស្សបន្តិចម្តងបន្តិចរហូតបាត់ចេញពីយើង (សាវ័កប៉ុលប្រាប់លោកធីម៉ូថេ) ***គឺក្នុងពួកជំនុំនៃព្រះដ៏មានព្រះជន្មរស់ ដែលជាសសរ ហើយជាជើងថ្កល់របស់សេចក្តីពិត*** ធីម៉ូថេទី១ ៣:១៥

ខ្ញុំចង់បញ្ចប់នៅចំណុចរបស់ខ្ញុំនូវចំណុចទាំងនេះ តើយើងកំពុងបង្រៀនព្រះបន្ទូលពិតរបស់ព្រះឬទេ? គ្រប់ទិដ្ឋភាពនៃដំណឹងល្អអំពីនគររបស់ព្រះគឺសំខាន់ ប៉ុន្តែមានចំណុចសំខាន់ៗជាច្រើនដែលធ្វើឲ្យទទួលគ្រោះថ្នាក់ ការភ័យខ្លាច មនុស្សជុំវិញបដិសេធយើង ឬគេមកសម្លុតយើងឲ្យស្ងាត់? ដូចសាវ័កប៉ុលតែងតែប្រកាសដំណឹងជានិច្ចផងដែរ ក្នុងព្រះគម្ពីរកិច្ចការ ២០:២០ និង២៧

«ក៏ដឹងថា ខ្ញុំមិនបានខាននឹងប្រាប់សេចក្តីអ្វី ដែលមានប្រយោជន៍ដល់អ្នករាល់គ្នាដែរ ....ព្រោះខ្ញុំមិនបានខាននឹងប្រាប់អ្នករាល់គ្នា ពីគ្រប់ទាំងគំនិតរបស់ព្រះទេ»

ចំនុចសំខាន់របស់យើងដែលត្រូវដឹងគឺថា ជាអ្នកស្វែងរក និងជាអ្នកប្រកាសសេចក្តីពិត បង្រៀនតាមពួកជំនុំ បង្រៀនមនុស្សផ្សេងៗ ដោយសេចក្តីសប្បុរស ដើម្បីឲ្យជីវិតរបស់យើងបានឆ្លុះបញ្ចាំង និងបង្ហាញការពិត ការអាណិតអាសូរនោះ ក្នុងការនាំមកនូវសេរីភាព និងផ្តល់អំណាចដល់មនុស្សឱ្យរស់នៅបានល្អ ដែលមកពីព្រះវិញ។